ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
១១១១១

សំណុំរឿង ព្រហ្មទណ្ឌ
លេខ : ៤០
ចុះថ្ងៃទី១៧ខែកក្កដា ឆ្នាំ២០០០

សាលដីកា
លេខ : ៣៤
ចុះថ្ងៃទី២១ខែកក្កដា ឆ្នាំ២០០០

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០០០ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :-

១- ឯកឧត្តម ឃឹម ប៉ុណ្ណ ប្រធាន
២- លោក ឈឹម ស៊ីផល ចៅក្រម
៣- លោក ប្រាក់គឹមសាន ចៅក្រម រេឃយការណ៍
៤- លោក ស៊ិន ឌីម ចៅក្រម
៥- លោក ជីវ កេង ចៅក្រម

ក្រឡាបញ្ជី

លោក អ៊ូ សុផុន

តំណាងមហាអយ្យការ

ឯកឧត្តម ដួន ស៊ីនទៀង អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលេខ ៣៨ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០០ របស់លោកមេធាវី សៅ វីតា ការពារអោយជនជាប់ចោទឈ្មោះ យុន សាវុធ និង បណ្តឹងសាទុក្ខលេខ ៧១ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០០ របស់ឈ្មោះ វ៉ាន់ ដារ៉ាសិទ្ធ ដែលប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ ១០០ ចុះថ្ងៃទី០៧ ខែ មេសា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល និង សំណុំរឿងព្រហ្មទណ្ឌលេខ ៤០ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០០ របស់តុលាការកំពូល ។

ពីបទ : ក្លែងបញ្ញើរត្រារក្ខាប្រមាញ់ ប្រើបញ្ញើរត្រារក្ខាប្រមាញ់ក្លែងក្លាយ ដឹកជញ្ជូនឈើចេញក្រៅប្រទេសគ្មានលិខិតអនុញ្ញាតបង្ហិចបង្ខាញទ្រព្យសម្បត្តិរដ្ឋ ប្រព្រឹត្តនៅខេត្តមណ្ឌលគិរី កាលពីថ្ងៃទី១១.១២.១៩៩៩ ។

១- ជនជាប់ចោទឈ្មោះ យុន សាវុធ " ជាម្ចាស់បណ្តឹងសាទុក្ខ " ភេទ ប្រុស អាយុ ៤៤ ឆ្នាំ ជាតិ ខ្មែរ មុខរបរ នគរបាល កើតនៅភូមិរជាទី ឃុំ ក្រញូង ស្រុក កំចាយមារ ខេត្ត ព្រៃវែង មានទីលំនៅបច្ចុប្បន្នក្រុមទី ៤ ភូមិ សន្សំកុសលទី ២ សង្កាត់ បឹងទំពុន ខណ្ឌ មានជ័យ ក្រុង ភ្នំពេញ ។ ឪពុកឈ្មោះ

ឌុច ឃុន " ទ " ម្តាយឈ្មោះ ផាត់ ហ៊ុំ " ទ " ប្រពន្ធឈ្មោះ នោម សុខា មានកូន ០២នាក់ ទោសពីមុនគ្មាន ។

២ - ជនជាប់ចោទឈ្មោះ វ៉ាន់ ផារ៉ាសិទ្ធ " ជាម្ចាស់បណ្តឹងសាទុក្ខ " ភេទ ប្រុស អាយុ ៤០ ឆ្នាំ ជាតិ ខ្មែរ មុខរបរ កងរាជអាវុធហត្ថ កើតនៅភូមិទី ១ ឃុំទី ១ ស្រុក ស្ទឹងត្រែង ខេត្ត ស្ទឹងត្រែង មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ៨សេ ផ្លូវ ២៧១ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌ ទួលគោក ក្រុង ភ្នំពេញ ។ ឪពុកឈ្មោះ ជៀន សេង " ទ " ម្តាយឈ្មោះហាក់អេង " ទ " ប្រពន្ធឈ្មោះ កែវ ស្រីមុិច មានកូន ០៤នាក់ ទោសពីមុនគ្មាន ។

មេធាវីលោក ខៀវ សុផល ការពារអោយជនជាប់ចោទ

ដើមបណ្តឹងរដ្ឋប្បវេណីអ្នកស្រី សឹង សុិនឌី " ជាចុងបណ្តឹងសាទុក្ខ " អាយុ ៥៥ឆ្នាំ ជាតិ ខ្មែរ មុខរបរ ប្រធាន ការិយាល័យចាត់តាំងនាយកដ្ឋានរុក្ខាប្រមាញ់ នៃក្រសួងកសិកម្ម មានទីលំនៅពុ ផ្ទះលេខ ៧៣អឺសូន្យ ផ្លូវ ១២២ សង្កាត់ ផ្សារដេប៉ូទី ៣ ខណ្ឌ ទួលគោក ក្រុង ភ្នំពេញ ។

មេធាវី គ្មាន

- តាមបណ្តឹងសាទុក្ខលេខ ៣៨ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០០ របស់លោកមេធាវី សៅ វីតា ការពារអោយជនជាប់ចោទឈ្មោះ ឃុន សាវុធ ដែលប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ ១០០ ចុះថ្ងៃទី០៧ខែ មេសា ឆ្នាំ ២០០០របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- តាមបណ្តឹងសាទុក្ខលេខ ៧១ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០០ របស់ឈ្មោះ វ៉ាន់ ផារ៉ាសិទ្ធ ដែលប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ ១០០ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- តាមរបាយការណ៍លេខ ៥០៧០កសកបរប ចុះថ្ងៃទី ១៦.១២.១៩៩៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បញ្ជាក់ថា ប្តឹងពីអាជ្ញាធរខេត្ត មណ្ឌលគិរី ប្រធាននគរបាល ប្រធាន កងរាជអាវុធហត្ថ និង ប្រធាន ប្រតិបត្តិការសឹករងខេត្ត ពីបទៈ ប្រើប្រាស់លិខិតក្លែងលួចកាប់ឈើ និង នាំឈើចេញក្នុងតំបន់ប៊ូស្រា អូរង្គៀយ អូតាម៉ែ ក្នុងស្រុក ពេជ្រដា ខេត្ត មណ្ឌលគិរី ហើយព្រមទាំងផ្តល់សំភារៈអាជីវកម្មដល់ក្រុមហ៊ុនឃុន តេ ហាស់ កា ទៀតផង ។

បានឃើញដីកាសំរេចលេខ ១០៨៣តព្រ ចុះថ្ងៃទី ០១.០៣.២០០០ របស់ចៅក្រមស៊ើបអង្កេត តុលាការក្រុងភ្នំពេញ ដែលបានសំរេច :-

១ - អោយឈ្មោះ វ៉ាន់ ផារ៉ាសិទ្ធិ អាយុ ៤០ ឆ្នាំ ភេទប្រុស ជាតិ ខ្មែរ របររសុី មេបញ្ជាការរងកងរាជអាវុធហត្ថប្រចាំខេត្តមណ្ឌលគិរី ដែលជាប់ចោទពីបទក្លែងញញួរត្រារុក្ខាប្រមាញ់ និង ប្រើញញួរត្រារុក្ខាប្រមាញ់ក្លែងក្លាយ បទដឹកជញ្ជូនឈើចេញក្រៅប្រទេសគ្មានលិខិតអនុញ្ញាតិ និង បទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរដ្ឋដោយចេតនា ប្រព្រឹត្តនៅខេត្ត

--- ---

មណ្ឌលគិរី កាលពីខែ ១១.១២ ឆ្នាំ ១៩៩៩ តាមមាត្រាទី ៣៧ , ៣៣ នៃច្បាប់ស្តីពីការគ្រប់គ្រងវិស័យព្រៃឈើ និង ប្រការ ៥ នៃក្រឹត្យច្បាប់លេខ ០២ បាននៅក្រៅឃុំជាបណ្តោះអាសន្ន ។

២ - បង្គាប់មកលោកប្រធានមន្ទីរឃុំឃាំង គ១ នៃក្រសួងមហាផ្ទៃអោយដោះលែងឈ្មោះនេះជាបន្ទាន់ប្រសិនបើឈ្មោះនេះមិនត្រូវជាប់ខ្លួនពីបទល្មើសផ្សេងទៀតទេ តែត្រូវអោយឈ្មោះនេះចូលទៅកាន់តុលាការជាដរាបកាលបើមានដីកាកោះហៅ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ ០២ " យ " ចុះថ្ងៃទី ០២.០៣.២០០០របស់លោក ម៉ែង សារ៉ាត ព្រះរាជអាជ្ញារង អមតុលាការក្រុងភ្នំពេញ ដែលប្តឹងតវ៉ាពីដីកាសំរេចលេខ ១០៨៣តព្រ ចុះថ្ងៃទី ០១.០៣.២០០០ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញដីកាសំរេចលេខ ១១.១៩ត.ព្រ ចុះថ្ងៃទី ០៣.០៣.២០០០របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ដែលបានសំរេច :-

បដិសេធពាក្យសុំធានានៅក្រៅឃុំបណ្តោះអាសន្ន ចុះថ្ងៃទី០១.០៣.២០០០ របស់ឈ្មោះ សៅ វីតា និង ឈ្មោះ ខៀវ សុផល ជាមេធាវីការពារអោយជនជាប់ចោទឈ្មោះ យុន សាវុធ ភេទប្រុស អាយុ ៤៤ ឆ្នាំ ពីបទ ក្លែងញញួរត្រារក្ខាប្រមាញ់ និងប្រើញញួរត្រារក្ខាប្រមាញ់ក្លែងក្លាយ ពីបទដឹកជញ្ជូនឈើចេញក្រៅប្រទេស គ្មានលិខិតអនុញ្ញាត ពីបទបំផ្លិចបំផ្លាញ ទ្រព្យសម្បត្តិរដ្ឋដោយចេតនា ប្រព្រឹត្តនៅខេត្តមណ្ឌលគិរី កាលពីខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ០៣ " យ " ចុះថ្ងៃទី ០៩.០៣.២០០០ របស់លោក សៅ វីតា មេធាវីការពារអោយជនជាប់ចោទ ដែលប្តឹងតវ៉ាពីដីកាសំរេចលេខ ១១.១៩តព្រ ចុះថ្ងៃទី ០៣.០៣.២០០០ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថា :-

១ - ទទួលបណ្តឹងឧទ្ធរណ៍លេខ ០២ " យ " ចុះថ្ងៃទី ០២.៣.២០០០ របស់លោក ម៉ែង សារ៉ាត់ ទុកជាត្រឹមត្រូវតាមទំរង់ និងនីតិច្បាប់ ។

២ - បដិសេធបណ្តឹងរបស់លោក មេធាវី សៅ វីតា ចោលជាអាសារបង់ ។

៣ - បដិសេធដីកាសំរេចលេខ ១០៨៣ តព្រ. ០១.៣.២០០០ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ចោលជាអាសារបង់ ។

៤ - បន្តការឃុំខ្លួនលើឈ្មោះ វ៉ាន់ ដារ៉ាសិទ្ធិ ជាបណ្តោះអាសន្ន ។

----- -----

បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ១០០ ចុះថ្ងៃទី០៧.០៤.២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :-

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០២.៣.២០០០ របស់ព្រះរាជអាជ្ញា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២-ទទួលបណ្តឹងឧទ្ធរណ៍ របស់លោក មេធាវី ចុះថ្ងៃទី០៨.៣.២០០០ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយទាស់នឹងគតិច្បាប់ ។

៣-សំរេចបដិសេធដីកាសំរេចលេខ ១០៨៣ តព្រ ចុះថ្ងៃទី០១.៣.២០០០ ដែលអោយជនល្មើសឈ្មោះ ខ៊ាន់ ដារ៉ាសិទ្ធិ នៅក្រៅឃុំ បណ្តោះអាសន្ន របស់ចៅក្រមស៊ើបអង្កេត ចោល ។

៤-សំរេចតម្កល់ដីកាសំរេចលេខ ១១១៩តព្រ ចុះថ្ងៃទី០៣.៣.២០០០ របស់ចៅក្រមស៊ើបអង្កេត ទុកជាបានការទាំងមូល មិនអនុញ្ញាតិអោយឈ្មោះ ឃុន សាវុធ នៅក្រៅឃុំ ។

៥-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខ មេធាវីជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងតវ៉ា ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣៨ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០០ របស់លោកមេធាវី សៅ វីតា ការពារអោយជនជាប់ចោទឈ្មោះ ឃុន សាវុធ ដែលប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ ១០០ ចុះថ្ងៃទី០៧ ខែ មេសា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញបណ្តឹងសាទុក្ខលេខ ៧១ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០០ របស់ឈ្មោះ ខ៊ាន់ ដារ៉ាសិទ្ធិ ដែលប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ ១០០ ចុះថ្ងៃទី០៧ ខែ មេសា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសារណា ចុះថ្ងៃទី ១៨.០៧.២០០០ របស់លោក ខៀវ សុផល មេធាវីការពារអោយជនជាប់ចោទ ធ្វើទៀងត្រឹមត្រូវតាមកំណត់ច្បាប់ ។

បានឃើញសារណាតប ចុះថ្ងៃទី ១៩.០៧.២០០០ របស់គណៈកម្មការចំរុះអន្តរក្រសួង ស្រាវជ្រាវបទល្មើសព្រៃឈើនៅខេត្តមណ្ឌលគីរី ធ្វើទៀងត្រឹមត្រូវតាមកំណត់ច្បាប់ ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា :

គប្បីសំរេចអោយជនជាប់ចោទ នៅក្រៅឃុំជាបណ្តោះអាសន្នតាមពាក្យសុំធានា ។

សាលដីការបស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈខុស

--- ---

ស្តង់ទៅនឹងគតិច្បាប់ ។

បានស្តាប់អំណានសារណារបស់ជនជាប់ចោទឈ្មោះ ឃុន សាវុធ និង វ៉ាន់ ដារ៉ាសិទ្ធិ " ជាម្ចាស់បណ្តឹងសាទុក្ខ " នាពេលជំនុំជំរះ ។

បានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ សឹង សិុនឌី " ជាចុងបណ្តឹងសាទុក្ខ " នាពេលជំនុំជំរះថា: ខ្លួន គ្រាន់តែជាមន្ត្រី កាន់ញញួរត្រារបស់នាយកដ្ឋានរុក្ខាប្រមាញ់ នៅថ្ងៃទី ៨.២.២០០០ ខ្លួន បានចូលមកតុលាការក្រុងភ្នំពេញ ធ្វើពាក្យបណ្តឹងពីជនដែលធ្វើញញួរត្រាក្លែងក្លាយដឹកជញ្ជូនឈើ ដោយគ្មានច្បាប់អនុញ្ញាត ។ នៅខេត្ត មណ្ឌលគិរី ញញួរត្រានេះគឺលោក ទី ឃឿន ជាអ្នកគ្រប់គ្រង ក្រោយមកដោយមានភាពអាណាធិបតេយ្យ ក្នុងការកាប់ព្រៃឈើ ក្រសួងក៏ដកយកញញួរត្រាពីខេត្តមណ្ឌលគិរី មកទុកវិញនៅឆ្នាំ ៩៨ ហើយញញួរត្រាខ្លួន ជាអ្នករក្សាទុក ។ ហើយនៅពេលថ្មីៗនេះមានស្នាមញញួរត្រាវាយលើឈើក្លែងក្លាយ ចំពោះការប្តឹងរបស់ខ្លួននេះ គឺប្តឹងសុំអោយតុលាការរកជនក្លែងញញួរត្រា ពុំមែនលើបុគ្គលណាមួយទេ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ខៀវ សុផល មេធាវីការពារអោយជនជាប់ចោទ នាពេលជំនុំជំរះបានលើកឡើងថា: ក្នុងការសុំអោយនៅក្រៅឃុំបណ្តោះអាសន្ន គឺជារឿងដែលមានច្បាប់កំណត់ត្រឹមត្រូវដូចជាកំណត់ពេលនៃការឃុំខ្លួន បណ្តោះអាសន្នការកំណត់លក្ខខណ្ឌទាំងឡាយអោយនៅក្រៅឃុំ បាននិងការកំណត់អំពីសំណូមពររបស់ដើមបណ្តឹង ។ ក្នុងករណីនេះ កូនក្តីខ្លួន មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដូចការបកស្រាយជូនខាងលើដែលធ្វើអោយតុលាការសំរេចអោយនៅក្រៅឃុំបណ្តោះអាសន្នបាន ។

ខ្លួនសូមសំណូមពរឯកឧត្តម មេត្តាបដិសេធសាលដីកាលេខ ១០០ ចុះថ្ងៃទី៧ ខែ មេសា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ចោលជាអសារបង់ ។ រួចសំរេចដោះលែងកូនក្តីខ្លួនឈ្មោះ ឃុន សាវុធ និង វ៉ាន់ ដារ៉ាសិទ្ធិ អោយនៅក្រៅឃុំបណ្តោះអាសន្នតាមច្បាប់ ។

បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូល នាពេលសវនាការថា: សូមតម្កល់សេចក្តីសន្និដ្ឋានរបស់ខ្លួន នៅដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណារបស់ជនជាប់ចោទ , ចម្លើយរបស់អ្នកស្រី សឹង សិុនឌី និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ ។
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣៨ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០០របស់លោក សៅ វីតា មេធាវីការពារអោយជនជាប់ចោទឈ្មោះ ឃុន សាវុធ

--- ---

និង បណ្តឹងសាទុក្ខលេខ ៧១ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០០របស់ជនជាប់ចោទឈ្មោះ វ៉ាន់ ផាវ៉ាសិទ្ធ ធ្វើទៅឡើងក្នុងកំណត់ច្បាប់តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបាន តាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍មិនអនុញ្ញាតអោយជនជាប់ចោទ នៅក្រៅឃុំបណ្តោះអាសន្នដោយអាងហេតុថា បទល្មើសនេះទាក់ទងនឹងទ្រព្យសម្បត្តិរដ្ឋដែល មានទាក់ទងគ្នាជាខ្សែសង្វាក់ហើយការស៊ើបអង្កេតក៏ពុំទាន់ជឿនលឿនផងនោះជាការពុំត្រឹម ត្រូវទេពីព្រោះសំអាងហេតុនេះពុំមែនជាលក្ខខណ្ឌដែលត្រូវតែឃុំខ្លួន ដូចមានចែងនៅក្នុងមាត្រា ១៤ ចំណុច១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលទេឡើយ ។

- យល់ឃើញថា តាមលិខិតចុះថ្ងៃទី ២៤.៤.២០០០ , ០៣.៧.២០០០ និង លិខិតចុះថ្ងៃទី១៧.៧.២០០០របស់សមាជិករដ្ឋសភា និង ព្រឹទ្ធសភា នៅភូមិភាគឥសានទាំងអស់ ចំនួន ០៥រូបបានសុំធានាមន្ត្រីរាជការនៅខេត្តមណ្ឌលគិរី ក្នុងនោះមានឈ្មោះ ឃុន សាវុធ និង ឈ្មោះ វ៉ាន់ ផាវ៉ាសិទ្ធ ដែលពាក់ព័ន្ធបញ្ហាដីព្រៃឈើ ហើយកំពុងឃុំខ្លួនបណ្តោះអាសន្នអោយ នៅក្រៅឃុំបណ្តោះអាសន្នដោយសន្យាថា បើឈ្មោះនេះពិតជាមានកំហុសមែននោះធានា បញ្ជូនមកទទួលទោសវិញ ហើយតាមសារណាតបចុះថ្ងៃទី ១៩.៧.២០០០ គណៈកម្មការចំរុះអន្តរ ក្រសួង ដើម្បីស្រាវជ្រាវបទល្មើសដីព្រៃឈើនៅខេត្តមណ្ឌលគិរី បានឯកភាពអោយជនជាប់ចោទ នៅក្រៅឃុំជាបណ្តោះអាសន្នដែរ ដូច្នេះយោងតាមសំណើសុំធានារបស់ឥស្សរជនខាងលើ និង ការឯកភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីតុលាការកំពូល គប្បីអនុញ្ញាតតាមពាក្យសុំអោយជនជាប់ ចោទ នៅក្រៅឃុំជាបណ្តោះអាសន្ន ។

- យល់ឃើញថា ជនជាប់ចោទបានផ្ញើសារណាការពាររឿងក្តីរបស់ខ្លួន ជូនតុលាការកំពូលរួចហើយ ហើយក៏បានទទួលដីកាកោះរួចហើយដែរ ប៉ុន្តែពុំបានមកចូលរួមនាសវនា ការនេះទេ ដូច្នេះតុលាការកំពូល ជំនុំជំរះរឿងនេះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១០០ ចុះថ្ងៃទី០៧.៤.២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខអ្នកស្រី ស៊ឹង ស៊ិនឌី កំបាំងមុខ

ជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

១ - ទទួលបណ្តឹងសាទុក្ខលេខ ៣៨ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០០ របស់លោក សៅ វីតា មេធាវីការពារអោយជនជាប់ចោទឈ្មោះ ឃុន សាវុធ និង បណ្តឹង សាទុក្ខលេខ ៧១ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០០ របស់ឈ្មោះ វ៉ាន់ ផាវ៉ាសិទ្ធ ទុកជា ត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

----- ---

២ - ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ ១០០ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ទាំងមូលដោយឥតបង្អិល ។

៣ - សំរេចដោះលែងជនជាប់ចោទឈ្មោះ ឃុន សាវុធ និង ឈ្មោះ ទ៉ាន់ ដារ៉ាសិទ្ធ អោយនៅក្រៅឃុំជាបណ្ដោះអាសន្នតាមពាក្យសុំប្រសិនបើឈ្មោះទាំងពីរនេះពុំមានជាប់ឃុំពីបទផ្សេងទៀតទេ ។

៤ - បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ៤០ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០០ របស់តុលាការកំពូល ទៅតុលាការក្រុងភ្នំពេញដើម្បីចាត់ការតាមនីតិវិធី ។

៥ - សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០ ។